**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ៣៤៤នាក់ និងមានករណីជាសះស្បើយ ចំនួន ២៩នាក់ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤៤៨ | ១២២ | ៣២៦ | អ្នកឆ្លងថ្មី៖ **០៤នាក់** |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩៤ | ៧០ | ២៤ | អ្នកឆ្លងថ្មី៖ **០១នាក់** |
| | ១.៣.ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ៤៦៧៦ | ២៦៧៨ | ១៩៩៨ | អ្នកឆ្លងថ្មី៖ **៣៣៩នាក់** |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៥២១៨** | **២៨៧០** | **២៣៤៨** | អ្នកឆ្លងថ្មី៖ **៣៤៤នាក់** |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤៣៣ | ១១៦ | ៣១៧ | អ្នកជាថ្មី៖ **០១នាក់** |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩១ | ៦៩ | ២២ | អ្នកជាថ្មី៖ ០នាក់ |
| | ២.៣. ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ១៧៩៥ | ៨៨៣ | ៩១២ | អ្នកជាថ្មី៖ **២៨នាក់** |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **២៣១៩** | **១០៦៨** | **១២៥១** | អ្នកជាថ្មី៖ **២៩នាក់** |
| ៣. | **ករណីអ្នកស្លាប់៖** | | | | |
| | ៣.១.អ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ | ៣៦ | ១៦ | ២០ | អ្នកស្លាប់ថ្មី៖ **០១នាក់** |
| | **សរុបករណីអ្នកស្លាប់** | **៣៦** | **១៦** | **២០** | |


ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៤ ៩៧០ / ៨៨៤ ៩០៩

| | | | | | |
|---|---|---|---|---|---|
| | ៤.៣០.មណ្ឌលព្យាបាលវិទ្យាល័យជាស៊ីម សាមគ្គី | ៥៤ | ៤៦ | ០៨ | |
| | ៤.៣១. មណ្ឌលព្យាបាល អនុវិទ្យាល័យពោធិ៍ចិនតុង | ៤៤ | ៣៣ | ១១ | |
| | ៤.៣២. ព្យាបាលនៅផ្ទះ | ១៧ | ១០ | ០៧ | |
| | ៤.៣៣. រងចាំបញ្ជូនទៅកន្លែងសម្រាក | ១៦៥៥ | ១១៣១ | ៥២៤ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **២៨៥៨** | **១៧៨៤** | **១០៧៤** | |

## ២. ព័ត៌មានប្រចាំថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១

**ក. មានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ សរុបចំនួន ៣៤៤នាក់**

**ក.១. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០៤នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)**

- បុរសជនជាតិឥណ្ឌូនេស៊ី អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូនេស៊ី បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១។
- បុរសជនជាតិឥណ្ឌូនេស៊ី អាយុ ៤២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូនេស៊ី បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១។
- បុរសជនជាតិឥណ្ឌូនេស៊ី អាយុ ៣៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូនេស៊ី បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១។
- បុរសជនជាតិឥណ្ឌូនេស៊ី អាយុ ១៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូនេស៊ី បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១។

**សម្គាល់៖** លទ្ធផលធ្វើតេស្តវត្ថុសំណាក របស់បុគ្គលទាំង **០៤នាក់**ខាងលើនេះ ផ្តល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ គឺ វិជ្ជមានវីរុសកូវីដ-១៩។ អ្នកជំងឺ **០៤នាក់** ខាងលើនេះក្រសួងនឹងធ្វើការជូនដំណឹងបន្តទៀតនៅពេលទទួលបានកន្លែងសម្រាកព្យាបាល។

**ក.២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០១នាក់ ដែលជាពលករធ្វើដំណើរមកពីប្រទេសថៃ**

- បុរសជនជាតិខ្មែរ អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរៈភូមិន្ទ ខេត្តកោះកុង ជាអ្នកធ្វើដំណើរមកពីប្រទេសថៃ មកដល់កម្ពុជានៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១។ បច្ចុប្បន្នអ្នកជំងឺរូបនេះត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកោះកុង។

**ក.៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ៣៣៩នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ**

- ស្ត្រីជនជាតិខ្មែរ អាយុ ៣៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ។
- ស្ត្រីជនជាតិខ្មែរ អាយុ ៣០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ។

| | | | | | |
|---|---|---|---|---|---|
| ៤. | **អ្នកកំពុងសម្រាកព្យាបាល៖** | | | | |
| | ៤.១. មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន | ៤៣ | ២៣ | ២០ | |
| | ៤.២. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ២៧ | ១០ | ១៧ | |
| | ៤.៣. មណ្ឌលសុខភាពចាក់អង្រែ | ៣៧ | ២១ | ១៦ | |
| | ៤.៤. មន្ទីរពេទ្យខេត្តប៉ៃលិន | ០១ | ០១ | ០ | |
| | ៤.៥. មន្ទីរពេទ្យបង្អែក ខេត្តព្រះសីហនុ | ៧៩ | ៥០ | ២៩ | |
| | ៤.៦. សណ្ឋាគារសម័យថ្មីអន្តរជាតិ ខេត្តព្រះសីហនុ | ៣២ | ២៦ | ០៦ | |
| | ៤.៧. មន្ទីរពេទ្យបង្អែកជ័យជំនះខេត្ត កណ្ដាល | ៨៦ | ៥៣ | ៣៣ | |
| | ៤.៨. មណ្ឌលព្យាបាលស្រុកកោះធំ ខេត្តកណ្ដាល | ១៣ | ០២ | ១១ | |
| | ៤.៩. សណ្ឋាគារក្រេតឌុករាជធានីភ្នំពេញ | ២៩៤ | ១៧៤ | ១២០ | |
| | ៤.១០. មន្ទីរពេទ្យខេត្តកោះកុង | ១៧ | ០៣ | ១៤ | |
| | ៤.១១មន្ទីរពេទ្យបង្អែកបារាយណ៍-សន្ទុក ខេត្តកំពង់ធំ | ០១ | ០ | ០១ | |
| | ៤.១២. មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង | ២៤ | ១២ | ១២ | |
| | ៤.១៣. មន្ទីរពេទ្យខេត្តកំពង់ចាម | ០៦ | ០៤ | ០២ | |
| | ៤.១៤. មន្ទីរពេទ្យខេត្តសៀមរាប | ១៥ | ០៧ | ០៨ | |
| | ៤.១៥. មន្ទីរពេទ្យខេត្តកំពត | ០២ | ០២ | ០ | |
| | ៤.១៦. មន្ទីរពេទ្យខេត្តតាកែវ | ១៧ | ០៨ | ០៩ | |
| | ៤.១៧. មន្ទីរពេទ្យបង្អែកខេត្តកែប | ០១ | ០ | ០១ | |
| | ៤.១៨. មន្ទីរពេទ្យបង្អែកមេមត់ ខេត្តត្បូងឃ្មុំ | ០៣ | ០២ | ០១ | |
| | ៤.១៩. មន្ទីរពេទ្យស្វាយជ្រុំ ខេត្តស្វាយរៀង | ១២៤ | ៤២ | ៨២ | |
| | ៤.២០. មន្ទីរពេទ្យសាមគ្គីរំដួលខេត្តស្វាយរៀង | ១៣ | ០៦ | ០៧ | |
| | ៤.២១. មណ្ឌលព្យាបាលកូវីដ-១៩ ក្រុងបាវិត | ៩២ | ៣៥ | ៥៧ | |
| | ៤.២២. មន្ទីរពេទ្យកុមារជាតិ | ០១ | ០១ | ០ | |
| | ៤.២៣. មន្ទីរពេទ្យហ្លួងម៉ែ | ១៤៥ | ៧៦ | ៦៩ | |
| | ៤.២៤. មន្ទីរពេទ្យខេត្តកំពង់ឆ្នាំង | ០២ | ០ | ០២ | |
| | ៤.២៥. មន្ទីរពេទ្យខេត្តពោធិ៍សាត់ | ០៧ | ០២ | ០៥ | |
| | ៤.២៦. មន្ទីរពេទ្យខេត្តក្រចេះ | ០៣ | ០៣ | ០ | |
| | ៤.២៧. មន្ទីរពេទ្យខេត្តព្រះវិហារ | ០១ | ០១ | ០ | |
| | ៤.២៨. មន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ | ០១ | ០ | ០១ | |
| | ៤.២៩. មន្ទីរពេទ្យបង្អែកបាត់ដំបង | ០១ | ០ | ០១ | |



ទីស្ដីការក្រសួងសុខាភិបាល ផ្ទះលេខ ៨០ វិថីសម្ដេចប៉ែននុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៩ ៩៧០ / ៨៨៤ ៩០៩

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ **០២នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តក្រចេះ។

- ស្ត្រីជនជាតិខ្មែរ អាយុ ៣១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំស្មោរ ស្រុកព្រៃកប្បាស ខេត្តតាកែវ។
- កុមារីជនជាតិខ្មែរ អាយុ ១២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំស្មោរ ស្រុកព្រៃកប្បាស ខេត្តតាកែវ។
- បុរសជនជាតិខ្មែរ អាយុ ៤៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំស្មោរ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ **០៣នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តតាកែវ។

- ស្ត្រីជនជាតិខ្មែរ អាយុ ៤៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តសៀមរាប។

**ករណីវិជ្ជមាននៅ ខេត្តកណ្តាល សរុបចំនួន ០៨នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➤ ជនជាតិខ្មែរ ចំនួន ០៨នាក់ ស្ត្រី ០៥នាក់ និងបុរស ចំនួន ០៣នាក់

បច្ចុប្បន្នអ្នកជំងឺ **០៨នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល។

**ករណីវិជ្ជមាននៅ ខេត្តកោះកុង សរុបចំនួន ០៥នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➤ ជនជាតិចិន ចំនួន ០៥នាក់ ស្ត្រី ០១នាក់ និងបុរស ចំនួន ០៤នាក់

បច្ចុប្បន្នអ្នកជំងឺ **០៥នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកោះកុង។

**ករណីវិជ្ជមាននៅ ខេត្តព្រះសីហនុ សរុបចំនួន ០៦នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➤ ជនជាតិខ្មែរ ចំនួន ០៦នាក់ ស្ត្រី ០៣នាក់ និងបុរស ចំនួន ០៣នាក់

បច្ចុប្បន្នអ្នកជំងឺ **០៦នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ។

**ករណីវិជ្ជមាននៅ ខេត្តស្វាយរៀង សរុបចំនួន ៧១នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➤ ជនជាតិខ្មែរ ចំនួន ៤៤នាក់ ស្ត្រី ១៦នាក់ និងបុរស ចំនួន ២៨នាក់

បច្ចុប្បន្នអ្នកជំងឺ **៤៤នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលព្យាបាលកូវីដ-១៩ ក្រុងបាវិត។

➤ ជនជាតិខ្មែរ ចំនួន ១៣នាក់ ស្ត្រី ០៦នាក់ និងបុរស ចំនួន ០៧នាក់

បច្ចុប្បន្នអ្នកជំងឺ **១៣នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យសាមគ្គីរំដួល ខេត្តស្វាយរៀង។

➤ ជនជាតិខ្មែរ ចំនួន ១៤នាក់ ស្ត្រី ០៧នាក់ និងបុរស ចំនួន ០៧នាក់

បច្ចុប្បន្នអ្នកជំងឺ **១៤នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យស្វាយជ្រុំ ខេត្តស្វាយរៀង។

**ករណីវិជ្ជមាននៅ រាជធានីភ្នំពេញ សរុបចំនួន ២៤៣នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➤ ជនជាតិខ្មែរ ចំនួន ២៤១នាក់ ស្ត្រី ១៣៧នាក់ និងបុរស ចំនួន ១០៤នាក់

➤ ជនជាតិចិន ចំនួន ០២នាក់ ស្ត្រី ០១នាក់ និងបុរស ចំនួន ០១នាក់



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែននុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

អ្នកជំងឺចំនួន **២៤៣នាក់** ខាងលើក្រសួងនឹងធ្វើការជូនដំណឹងបន្តទៀតនៅពេលទទួលបានកន្លែងសម្រាកព្យាបាល។

**ខ. ករណីជាសះស្បើយ ៖ សរុបចំនួន ២៩នាក់**

**ខ.១ ករណីជាសះស្បើយ ៖ ចំនួន ០១នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)**

- បុរសជនជាតិឥណ្ឌូនេស៊ី អាយុ ៣៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខេត្តព្រះសីហនុ ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌូនេស៊ី បន្តជើងហោះហើរនៅប្រទេសសិង្ហបុរី មកដល់កម្ពុជានៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១។

**សម្គាល់៖** បុរសខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។

**ខ.២. ករណីជាសះស្បើយ ៖ ចំនួន ២៨នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ:**

- កុមារាជនជាតិខ្មែរ អាយុ ០៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
- បុរសជនជាតិខ្មែរ អាយុ ២៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
- ស្ត្រីជនជាតិខ្មែរ អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
- ស្ត្រីជនជាតិខ្មែរ អាយុ ៤៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

**សម្គាល់៖** បុគ្គល **០៤នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែកមេមត់ ខេត្តត្បូងឃ្មុំ។

- ស្ត្រីជនជាតិចិន អាយុ ៥៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។
- បុរសជនជាតិចិន អាយុ ៤២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។
- បុរសជនជាតិចិន អាយុ ៣៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខេត្តស្វាយរៀង។

**សម្គាល់៖** បុគ្គល **០៣នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យស្វាយជ្រុំ ខេត្តស្វាយរៀង។

- បុរសជនជាតិខ្មែរ អាយុ ៥៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។
- បុរសជនជាតិខ្មែរ អាយុ ២២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់គីឡូម៉ែតលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**សម្គាល់៖** បុគ្គល **០២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។

**ករណីជានៅ មណ្ឌលសុខភាពចាក់អង្រែ ចំនួន ០៧នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកជាសះស្បើយ៖**

➤ ជនជាតិខ្មែរ ចំនួន ០៧នាក់ ស្ត្រី ០៥នាក់ និងបុរស ០២នាក់

បុគ្គល **០៧នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ។

**ករណីជានៅ សណ្ឋាគារក្រេតខុក រាជធានីភ្នំពេញ ចំនួន ១២នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកជាសះស្បើយ៖**

➢ ជនជាតិខ្មែរ ចំនួន ១១នាក់ ស្ត្រី ០៦នាក់ និងបុរស ០៥នាក់

➢ ជនជាតិចិន ចំនួន ០១នាក់ ជាបុរស

បុគ្គល **១២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីសណ្ឋាគារក្រេតឌុក រាជធានីភ្នំពេញ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ធីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លង សហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ មន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប និងមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៃមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១



វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា